


# សេវាកម្មប្រាក់ឧបត្ថម្ភថ្លៃព្យាបាលសំរាប់ប្រជាជនអន្តោប្រវេសន៍ថ្មីនៃវេទិកាក្តីស្រលាញ់ក្រុងតៃប៉ិថ្មី

ចាប់ពីថ្ងៃទី១ខែមករាឆ្នាំ២០២០តទៅទីក្រុងតៃប៉ិថ្មីយើងខ្ញុំប្រកាសចេញសេវាកម្មប្រាក់ឧបត្ថម្ភថ្លៃព្យាបាលរបស់«វេទិកានៃក្តីស្រលាញ់គម្រោងយកចិត្តទុកដាក់លើប្រជាជនអន្តោប្រវេសន៍ថ្មី»។ប្រសិនបើលោកអ្នកជាជនអន្តោប្រវេសន៍ដែលឆ្លងដែនចូលមកស្នាក់នៅលើកដំបូងរយៈពេល៦ខែក្រោយរៀបអាពាហ៍ពិពាហ៍ប៉ុន្តែពុំទាន់មានធានារ៉ាប់រងសុខភាពជាតិហើយជាបុគ្គលដែលត្រូវរ៉ាប់រងថ្លៃព្យាបាលផ្ទាល់ខ្លួនដោយយថាហេតុឬមានជំងឺលោកអ្នកអាចអញ្ជើញមកកាន់ការិយាល័យចុះឈ្មោះគ្រួសារ(HouseholdRegistrationOffice)ណាមួយដែលនៅក្នុងទីក្រុងតៃប៉ិថ្មីក៏បានដើម្បីរៀបចំបែបបទស្នើសុំប្រាក់ឧបត្ថម្ភផ្នែកសុខាភិបាលដែលអាចជួយសម្រាលបន្ទុកហិរញ្ញវត្ថុរបស់លោកអ្នក។ប្រជាជនអន្តោប្រវេសន៍ថ្មីអាចធ្វើការស្នើសុំប្រាក់ឧបត្ថម្ភនេះក្រោយការកើតឡើងនៃមូលហេតុឧបត្ថម្ភថ្លៃព្យាបាលឬក្នុងរយៈពេល៦ខែគិតចាប់ពីថ្ងៃចេញវិក្កយបត្រថ្លៃព្យាបាល។ការិយាល័យចុះឈ្មោះគ្រួសារដែលទទួលករណីស្នើសុំនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចផ្តល់ជូននូវថវិកាឧបត្ថម្ភ។

### 1.បុគ្គលដែលអាចទទួលប្រាក់ឧបត្ថម្ភ ៖

ប្រជាជនអន្តោប្រវេសន៍ថ្មីជាសាមុីខ្លួនផ្ទាល់ស្នាក់នៅក្នុងក្រុងតៃប៉ិថ្មី(បុគ្គលដែលរៀបអាពាហ៍ពិពាហ៍ជាមួយប្រជាជនតៃវ៉ាន់)ឆ្លងដែនចូលមកស្នាក់នៅលើកដំបូងរយៈពេល៦ខែក្រោយរៀបអាពាហ៍ពិពាហ៍ប៉ុន្តែពុំទាន់មានធានារ៉ាប់រងសុខភាពជាតិហើយជាបុគ្គលដែលត្រូវរ៉ាប់រងថ្លៃព្យាបាលផ្ទាល់ខ្លួនដោយយថាហេតុឬមានជំងឺ។

### 2.ស្តង់ដាឧបត្ថម្ភ ៖

(1)សំរាប់បុគ្គលដែលរ៉ាប់រងថ្លៃព្យាបាលដោយខ្លួនឯងអស់ក្រោមឬស្មើ១ម៉ឺនលុយតៃវ៉ាន់នឹងផ្តល់ជូនប្រាក់ឧបត្ថម្ភ៥០%នៃថ្លៃព្យាបាលផ្ទាល់ខ្លួន។

(2)សំរាប់បុគ្គលដែលរ៉ាប់រងថ្លៃព្យាបាលផ្ទាល់ខ្លួនអស់ក្រោមឬពី១ម៉ឺនទៅ២ម៉ឺនលុយតៃវ៉ាន់នឹងផ្តល់ជូនប្រាក់ឧបត្ថម្ភ៦០%នៃថ្លៃព្យាបាលផ្ទាល់ខ្លួន។

(3)សំរាប់បុគ្គលដែលរ៉ាប់រងថ្លៃព្យាបាលផ្ទាល់ខ្លួនអស់ក្រោមឬពី២ម៉ឺនទៅ៣ម៉ឺនលុយតៃវ៉ាន់នឹងផ្តល់ជូនប្រាក់ឧបត្ថម្ភ៧០%នៃថ្លៃព្យាបាលផ្ទាល់ខ្លួន។

(4) សំរាប់បុគ្គលដែលរ៉ាប់រងថ្លៃព្យាបាលផ្ទាល់ខ្លួនអស់លើសពី៣ម៉ឺនលុយតៃវ៉ាន់ឬជាបុគ្គលដែលមានស្ថានភាពពិសេសនឹងផ្តល់ជូនប្រាក់ឧបត្ថម្ភ៨០%នៃថ្លៃព្យាបាលដោយខ្លួនឯងក្រោយពីទីស្តីការយើងខ្ញុំចុះហត្ថលេខាយល់ព្រមជាករណីពិសេស។

(5) សំរាប់បុគ្គលម្នាក់

ប្រាក់ឧបត្ថម្ភច្រើនបំផុត៥ម៉ឺនលុយតៃវ៉ាន់។

**3.របៀបស្នើសុំ :**

(1)ពេលវេលាស្នើសុំ៖ប្រជាជនអន្តោប្រវេសន៍ថ្មីជាសាម៉ីខ្លួនផ្ទាល់ត្រូវធ្វើការស្នើសុំក្រោយការកើតឡើងនៃមូលហេតុឧបត្ថម្ភថ្លៃព្យាបាលឬក្នុងរយៈពេល៦ខែគិតពីថ្ងៃចេញវិក្កយបត្រថ្លៃព្យាបាល។ប្រសិនបើសាម៉ីខ្លួនពុំអាចមកស្នើសុំដោយខ្លួនឯងផ្ទាល់ទេអាចផ្តល់សិទ្ធិអោយអ្នកដទៃជួយធ្វើការស្នើសុំជំនួសបាន។

(2)ស្ថាប័នស្នើសុំ៖លោកអ្នកអាចស្នើសុំនៅការិយាល័យចុះឈ្មោះគ្រួសារ(HouseholdRegistrationOffice)ណាមួយដែលនៅក្នុងទីក្រុងតៃប៉ិថ្មីក៏បាន។ការិយាល័យចុះឈ្មោះគ្រួសារដែលទទួលករណីស្នើសុំនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចផ្តល់ជូននូវថវិកាឧបត្ថម្ភ។

(3)ការពិនិត្យផ្ទៀងផ្ទាត់ក្របខណ្ឌធានារ៉ាប់រងសុខភាព៖ការិយាល័យដែលទទួលករណីស្នើសុំត្រូវពិនិត្យឃើញថាជនអន្តោប្រវេសន៍ថ្មីពិតជាពុំមានធានារ៉ាប់រងសុខភាពជាតិពិតមែនក្រោយឆ្លងដែនមកស្នាក់នៅ ៦ខែក្រោយរៀបអាពាហ៍ពិពាហ៍ព្រមទាំងពិនិត្យលើក្របខណ្ឌស្នើសុំ។

(4)ឯកសារដែលត្រូវការ :

1.បែបបទស្នើសុំ (លោកអ្នកអាចទាញយកតាមគេហទំព័រការិយាល័យក្រសួងកិច្ចការស៊ីវិលនៃរដ្ឋាភិបាលក្រុងតៃប៉ិថ្មី https://www.ca.ntpc.gov.tw ឬអញ្ជើញមកយកផ្ទាល់នៅការិយាល័យចុះឈ្មោះគ្រួសារ)។

2.លិខិតបញ្ជាក់ពីការព្យាបាល(Certificate ofDiagnosis)ពីមន្ទីរពេទ្យដែលស្ថិតនៅក្រោមក្រមខណ្ឌសុខាភិបាល។

3.វិក្កយបត្រច្បាប់ដើមនៃថ្លៃព្យាបាលពីមន្ទីរពេទ្យដែលស្ថិតនៅក្រោមក្រមខណ្ឌសុខាភិបាល។

4.កាតស្នាក់នៅ (ARC)ច្បាប់ដើម។

5.ក្របមុខសៀវភៅធនាគារច្បាប់កូពីរបស់ប្រជាជនអន្តោប្រវេសន៍ថ្មីជាសាម៉ីខ្លួនផ្ទាល់។

6.អត្តសញ្ញាណប័ណ្ណរបស់ប្រជាជនតៃវ៉ាន់ផ្ទាល់ច្បាប់ដើមសំរាប់អ្នកត្រូវបានពឹងពាក់អោយស្នើសុំជំនួសនិងលិខិតប្រគល់សិទ្ធិ។